ទូរសព្ទមកយើងខ្ញុំតាមលេខឥតគិតថ្លៃ៖

# 1-800-511-2300

ឬចូលទៅកាន់គេហទំព័រ៖

# dhcs.ca.gov/OPL

អង់គ្លេស អេស្បាញ អារ៉ាប់ អាមេនី កម្ពុជា/ខ្មែរ ចិនកាតាំង ហ្វាស៊ី ហិណ្ឌូ ម៉ុង ជប៉ុន កូរ៉េ ឡាវ ចិនកុកងឺ ពុនចាប៊ី រុស្ស៊ី តាហ្គាឡុក ថៃ និងវៀតណាម។
(មាន 24 ម៉ោង /7 ថ្ងៃ)

**ដើម្បីទទួលបានការធ្វើតេស្តពិនិត្យជំងឺមហារីកសុដន់ និងមាត់ស្បូនដោយឥតគិតថ្លៃទាំងនេះ អ្នកត្រូវតែ៖**

- រស់នៅក្នុងរដ្ឋ California ។
- បំពេញតាមលក្ខខណ្ឌតម្រូវស្តីពីអាយុ។
- គ្មាន ឬមានធានារ៉ាប់រងសុខភាពដែលមានកម្រិត។
- មានធានារ៉ាប់រងសុខភាពដែលមាន សហចំណាយ ឬប្រាក់ចំណាយត្រូវបង់មុនដែលអ្នក មិនអាចលៃលកបង់បាន ឬ
- មានប្រាក់ចំណូលក្នុងគ្រួសារទាប។

## សេចក្តីថ្លែងការណ៍ស្តីពីការមិនរើសអើង

ក្រសួងសេវាថែទាំសុខាភិបាលរដ្ឋ California គោរពតាមច្បាប់ស្តីពីសិទ្ធពលរដ្ឋរបស់សហព័ន្ធដែលត្រូវអនុវត្ត និងមិនរើសអើងដោយផ្អែកលើមូលដ្ឋានជាតិសាសន៍ ពណ៌សម្បុរ ប្រភពដើមជនជាតិ អាយុ ពិការភាព ឬភេទឡើយ។

Language Assistance Services

Si habla español, usted puede conseguir ayuda para entender este documento, hablando con su proveedor de atención primaria del programa EWC o llamando al Contratista Regional de su condado. Los teléfonos del Contratista Regional se encuentran abajo. Esta asistencia lingüística es gratis.

如果您說漢語，我們可以幫助您瞭解這份文檔。請諮詢您所在地EWC附近診所或當地負責聯絡人。當地負責人電話見下文，他們會免費提供說明服務。

1-800-511-2300
dhcs.ca.gov/EWC

© 2021 ក្រសួងសេវាថែទាំសុខាភិបាល រក្សាសិទ្ធិគ្រប់យ៉ាង។

Khmer

# ការពិនិត្យរកមើលជំងឺមហារីកសុដន់ និងមាត់ស្បូនដោយឥតគិតថ្លៃ

## ដោយកម្មវិធី EWC

## តើកម្មវិធី Every Woman Counts (EWC) គឺជាអ្វី?

កម្មវិធី EWC ផ្តល់សេវាពិនិត្យរកមើល និងតាមដានជំងឺមហារីកសុដន់ និងមាត់ស្បូនដោយឥតគិតថ្លៃ។ នេះរួមបញ្ចូលទាំងការថតសុដន់ តេស្តមាត់ស្បូន និង HPV ចំពោះអ្នកដែលមានសិទ្ធទទួលនៅក្នុងរដ្ឋ California។ នៅពេលមនុស្សកាន់តែចាស់ ឱកាសកើតជំងឺមហារីកសុដន់ និងមាត់ស្បូនក៏កើនឡើងផងដែរ នោះហើយជាមូលហេតុដែលពួកគេគួរតែឲ្យគេពិនិត្យរកមើលជំងឺមហារីកសុដន់ និងមាត់ស្បូនជាប្រចាំ។

## ហេតុអ្វីបានជាអ្នកគួរតែថតសុដន់?

- នៅពេលដែលជំងឺមហារីកសុដន់ត្រូវបានរកឃើញនៅដំណាក់កាលដំបូង វា ងាយស្រួលព្យាបាលជាង។
- ការថតសុដន់អាចរកឃើញជំងឺមហារីកសុដន់ដែលអ្នកឬគ្រូពេទ្យរបស់អ្នកមិនមានអារម្មណ៍ដឹងដោយសារវាតូចពេក។

## តើអ្នកគួរតែថតសុដន់ញឹកញាប់ប៉ុនណា?

- រៀងរាល់ 1 ឬ 2 ឆ្នាំម្តង ប្រសិនបើអ្នកអាយុ 40 ឆ្នាំឡើងទៅ។
- សូមនិយាយជាមួយគ្រូពេទ្យរបស់អ្នកអំពីពេលវេលា និងភាពញឹកញាប់ដែលអ្នកគួរឲ្យគេពិនិត្យ។

**1-800-511-2300**
**dhcs.ca.gov/OPL**

## កម្មវិធី EWC ផ្តល់ជូនឥតគិតថ្លៃនូវ៖

- ការថតសុដន់
- ការធ្វើតេស្តមាត់ស្បូន
- ការធ្វើតេស្ត HPV
- ការធ្វើតេស្តមាត់ស្បូន និង HPV រួមគ្នា
- ការធ្វើតេស្តតាមដាន ប្រសិនបើចាំបាច់

សូមនិយាយជាមួយគ្រូពេទ្យរបស់អ្នកអំពីពេលវេលា និងភាពញឹកញាប់ដែលអ្នកគួរឲ្យគេពិនិត្យរកមើលជំងឺមហារីកសុដន់ និងមាត់ស្បូន។

### សញ្ញាព្រមាន និង / ឬរោគសញ្ញាមួយចំនួននៃជំងឺមហារីកសុដន់រួមមាន៖

- ដុំ ពក ឬហើមនៅក្នុង សុដន់ ឬក្លៀក
- ការផ្លាស់ប្តូរទំហំ ឬរូបរាង សុដន់
- ការផ្លាស់ប្តូរស្ថានភាពស្បែក និងពណ៌ (មានស្នាមខួច ប៉ោង ស្នាមក្រហម ប្រេះស្រកា ឬការឡើងក្រាស់) នៃសុដន់ ឬក្បាលសុដន់
- ក្បាលសុដន់លិបចូលក្នុង ឬខ្ទាក់
- ការលេចចេញសារធាតុរាវចេញពីក្បាលសុដន់ និង/ឬ
- ឈឺសុដន់។

ប្រសិនបើអ្នកមានសញ្ញា ឬរោគសញ្ញាទាំងនេះ សូមទាក់ទងគ្រូពេទ្យរបស់អ្នកជាបន្ទាន់។

សូមកត់សម្គាល់ថា សញ្ញាព្រមាន និង/ឬ រោគសញ្ញាទាំងនេះអាចកើតឡើងដោយសារលក្ខខណ្ឌក្រៅពីជំងឺមហារីកសុដន់។

## ហេតុអ្វីបានជាអ្នកគួរធ្វើការពិនិត្យរកមើលជំងឺមហារីកមាត់ស្បូន?

- ការស្វែងរក និងព្យាបាលការផ្លាស់ប្តូរកោសិកានៅដំណាក់កាលដំបូង អាចការពារជំងឺមហារីកមាត់ស្បូនបាន។
- ការធ្វើតេស្តមាត់ស្បូន គឺជាការរកមើលការផ្លាស់ប្តូរកោសិកានៅក្នុង មាត់ស្បូនដែលអាចបង្កឱ្យមានជំងឺមហារីក។
- ការធ្វើតេស្ត HPV រកមើលមេរោគ ដែលអាចបណ្តាលឲ្យមានការផ្លាស់ប្តូរកោសិកានៅក្នុងមាត់ស្បូន។

## តើអ្នកគួរធ្វើការពិនិត្យរកមើលជំងឺមហារីកមាត់ស្បូនញឹកញាប់ប៉ុនណា?

- អ្នកដែលមានអាយុចាប់ពី 21 ឆ្នាំឡើងទៅគួរតែធ្វើតេស្តមាត់ស្បូនរៀងរាល់ 3 ឆ្នាំម្តង។
- អ្នកដែលមានអាយុចាប់ពី 30 ឆ្នាំឡើងទៅអាចជ្រើសរើសដើម្បីធ្វើ៖
  - តេស្ត HPV រៀងរាល់ 5 ឆ្នាំម្តង ឬ
  - តេស្តមាត់ស្បូន និង HPV រួមគ្នារៀងរាល់ 5 ឆ្នាំម្តង ឬ
  - តេស្តមាត់ស្បូនរៀងរាល់ 3 ឆ្នាំម្តង។

និយាយជាមួយគ្រូពេទ្យរបស់អ្នកថាតើជម្រើសមួយណាដែលត្រូវនឹងរូបអ្នក។